សេចក្តីប្រកាសព័ត៌មាន

**សមាគមនានារបស់រោងចក្រនៅអាស៊ីរួមកម្លាំងគ្នាដើម្បីឲ្យមានការអនុវត្តការទិញប្រសើរជាងមុននៅក្នុងឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរសម្លៀកបំពាក់**

*រាជធានីភ្នំពេញ/ដាក្កា/ប៉េកាំង/អ៊ីស្លាម៉ាបាដ/យ៉ាងហ្គោន/ហាណូយ៖ ថ្ងៃទី១៨ ខែមករា ឆ្នាំ២០២១*

**តំណាងនានានៃ STAR Network ដែលជាបណ្តាញអន្តរអាស៊ីទីមួយនៃសមាគមអ្នកផលិតក្នុងឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរសម្លៀកបំពាក់ បានរួមគ្នាកាលពីថ្ងៃអង្គារ ទី១២ ខែមករា ឆ្នាំ២០២១ ដើម្បីចាប់ផ្តើមគំនិតផ្តួចផ្តើមថ្មីមួយដែលអំពាវនាវឲ្យមានការទិញប្រសើរជាងមុននៅក្នុងឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរសម្លៀកបំពាក់។**

Miran Ali អ្នកនាំពាក្យតំណាង STAR Network បានថ្លែងថា៖ «យើងចង់រួមកម្លាំងគ្នាក្នុងនាមជាសមាគមនិងអ្នកផលិតនៅអាស៊ី ហើយឯកភាពគ្នាលើជំហររួមស្តីពីលក្ខខណ្ឌទូទាត់ប្រាក់និងប្រគល់ទំនិញ ដើម្បីឲ្យយើងមានសំឡេងខ្លាំងជាងមុនក្នុងការពិភាក្សាលក្ខណៈបុគ្គល និងលក្ខណៈរួម ជាមួយម៉ាកនិងអ្នកបញ្ជាទិញអំពីការកែលម្អការអនុវត្តការទិញ»។ ចំណុចពិសេសនៃគំនិតផ្តួចផ្តើមនេះគឺ វាជាការលើកឡើងនូវសំណួរនានាជុំវិញការអនុវត្តការទិញដូចជា លក្ខខណ្ឌនៃការទូទាត់ប្រាក់ និងការប្រគល់ទំនិញ ពីទស្សនៈវិស័យរបស់អ្នកផលិត និងសមាគមដែលតំណាងពួកគេ ដោយធ្វើឲ្យវាជាគំនិតផ្តួចផ្តើមអំពីការអនុវត្តជាក់ស្តែងពិតប្រាកដ ដែលអង្គការសមាជិកទាំងអស់ចំនួន៩ រួមមាន GMAC, BGMEA, BKMEA, CNTAC, PTMA, PHMA, TMA, MGMA និង VITAS គាំទ្រ។ Miran Ali ដែលប៉ាន់ប្រមាណថា បណ្តាញនេះតំណាងជាង៦០%នៃការនាំចេញសម្លៀកបំពាក់សកលរបស់រោងចក្រ បានថ្លែងបន្តថា៖ «ជំហររួមនេះនឹងមានអំណាច»។

ឧស្សាហកម្មវាយនភណ្ឌនិងកាត់ដេរសម្លៀកបំពាក់មានអតុល្យភាពអំណាចរវាងម៉ាកនិងអ្នកបញ្ជាទិញ ដោយមួយនៅម្ខាង និងមួយទៀតដែលជាអ្នកផលិតវាយនភណ្ឌនិងកាត់ដេរសម្លៀកបំពាក់នៅម្ខាងទៀត។ អតុល្យភាពនេះមានលក្ខណៈកាន់ខ្លាំងឡើង និងមើលឃើញកាន់តែច្បាស់ក្នុងអំឡុងជំងឺកូវីដ-១៩ ដែលក្នុងនោះ ការលុបចោលការបញ្ជាទិញ ជាពិសេសសពីអឺរ៉ុប និងម៉ាកអាមេរិក និងអ្នកបញ្ជាទិញ បានធ្វើឲ្យអ្នកផលិតនៅអាស៊ីជាច្រើនស្ថិតក្នុងស្ថានភាពដ៏លំបាក។ Miran Ali បានពន្យល់ថា៖ «ស្ថានភាពមានលក្ខណៈលំបាក»។ «ជំងឺកូវីដ-១៩បានផ្លាស់ប្តូរអ្វីៗគ្រប់យ៉ាង។ ទោះយ៉ាងណាក្តី វាមិនបញ្ចប់ជាមួយជំងឺកូវីដ-១៩ទេ!»។

រហូតដល់ខែមីនា ឆ្នាំ២០២១ សមាគមនានានឹងធ្វើការងារជាមួយគ្នាជាក្រុមការងារចំនួនប្រាំ ដោយកំណត់«បន្ទាត់ក្រហម» របស់ពួកគេ សំណើនិងអនុសាសន៍លើប្រធានបទនានាដូចជាការអនុវត្តលើការទូទាត់និងការប្រគល់ទំនិញ ការធ្វើផែនការ និងការដោះដូរព័ត៌មាន និងការបរោភាគីទី៣។ ផ្អែកតាមលទ្ធផលរបស់ក្រុមការងារ ជំហានទី២នៃគំនិតផ្តួចផ្តើមនេះនឹងជំរុញការអនុវត្តនៅក្នុងឧស្សាហកម្មនេះ។ អង្គការនិងបណ្តាញជាច្រើនក្នុងឧស្សាហកម្មនេះបានប្តេជ្ញាគាំទ្រគំនិតផ្តួចផ្តើមនេះរួចហើយ។ ពួកគេនឹងចូលរួមជាអ្នកជំនាញការ គាំទ្រក្រុមការងារ ឬជាផ្នែកនៃក្រុមប្រឹក្សាផ្តល់យោបល់ក្នុងឧស្សាហកម្មនេះ។

ទោះយ៉ាងណាក្តី មុនពេលម៉ាក អ្នកបញ្ជាទិញ និងភាគីពាក់ព័ន្ធដទៃៗចូលរួមតុពិភាក្សា រោងចក្រនិងសមាគមនឹងប្រើប្រាស់« លំហសុវត្ថិភាព»នៃគំនិតផ្តួចផ្តើមថ្មីរបស់ខ្លួនដើម្បីអភិវឌ្ឍលក្ខខណ្ឌតម្រូវនិងអនុសាសន៍រួមគ្នា ហើយបន្ទាប់មកប្រាស្រ័យទាក់ទងជាមួយពួកគេជាសំឡេងតែមួយ។

STAR Network ដើរតួជាវេទិកាសម្រាប់សំវាទនិងការបង្កើតទំនុកចិត្តដើម្បីដោះដូរយោបល់គ្នាអំពីការអនុវត្តល្អដើម្បីធ្វើឲ្យផលិតកម្មវាយនភណ្ឌនិងកាត់ដេរសម្លៀកបំពាក់មាននិរន្តរ៍ភាពជាងមុន។ បណ្តាញនេះត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១៦ ដោយមានការគាំទ្រពីទីភ្នាក់ងារសហប្រតិបត្តិការនិងអភិវឌ្ឍន៍អាល្លឺម៉ង់ )GIZ) ដែលអនុវត្តគម្រោងមួយហៅថា FABRIC Asia ដែលមានគោលបំណងជំរុញនិរន្តរ៍ភាពនៅក្នុងឧស្សាហកម្មវាយនភណ្ឌនិងសម្លៀកបំពាក់អាស៊ីតាងនាមឲ្យក្រសួងសហព័ន្ធអាល្លឺម៉ង់សម្រាប់កិច្ចសហប្រតិបត្តិការនិងការអភិវឌ្ឍន៍សេដ្ឋកិច្ច(BMZ)។ នៅដំណាក់កាលដំបូងនៃជំងឺកូវីដ-១៩ បណ្តាញ STAR Networkបានចេញសេចក្តីថ្លែងការណ៍រួមមួយរួចហើយ ដោយអំពាវនាវឲ្យមានការអនុវត្តការទិញដែលមានលក្ខណៈទទួលខុសត្រូវក្នុងអំឡុងវិបត្តិជំងឺកូវីដ-១៩ ដែលពួកគេបានចេញផ្សាយនៅលើគេហទំព័ររួមគ្នារបស់ពួកគេកាលពីខែមេសា ឆ្នាំ២០២០។

បន្ទាប់ពីសមាជិកទាំងអស់បញ្ជាក់អំពីការប្តេជ្ញាចិត្តរបស់ពួកគេ STAR និង GIZ FABRIC បានរួមកម្លាំងជាមួយសហព័ន្ធសម្លៀកបំពាក់អន្តរជាតិ(IAF)ដើម្បីបង្កើតគំនិតផ្តួចផ្តើមអនុវត្តការទិញនេះ។ IAF កំពុងទាក់ទងជាមួយសមាគមសមាជិក IAF ជាច្រើនបន្ថែមទៀតដែលកំពុងគ្រោងចូលរួមគំនិតផ្តួចផ្តើមនេះ។